ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះវិហារ

# សាលក្រមព្រហ្មទណ្ឌ

# គាននាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌលេខ ១៨៦
ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧
សំណុំរឿងជំនុំជម្រះលេខ ៣៦
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨
សាលក្រមព្រហ្មទណ្ឌលេខ ៣៦ "ឃ"
ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨

សាលាដំបូងខេត្តព្រះវិហារ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ១០:៣៥ នាទីព្រឹក ដោយមានសមាសភាព៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះវិហារ

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៨៦ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទឈ្មោះ [redacted] លេង ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ [redacted] (ស)ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣៨១ គព្រ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ។

ជាប់ចោទពីបទ **រំលោភសេពសន្ថវៈ(ស្ថានទម្ងន់ទោសដោយសារមូលហេតុអាយុជនរងគ្រោះ)** ប្រព្រឹត្តនៅភូមិគុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំណុច ១ នៃក្រមព្រហ្មទណ្ឌ។

-លោក [redacted]វិន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិគុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ មានទីលំនៅបច្ចុប្បន្ន[redacted](វ) នៅលីវ ទោសពីមុនគ្មាន ជាអនីតិជន។



Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិក្តុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ មា[redacted](រ)ម្ដាយឈ្មោះ [redacted](ស) ប្តីឈ្មោះ[redacted]) មានកូនចំនួន០៧នាក់ ទោសពីមុនគ្មាន ជាទីតិជន។

-លោកស្រី [redacted]ជាតា ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤២ ដ.ស.ព/១៨ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងខេត្តព្រះវិហារ។

បានឃើញដីកាដំណោះស្រាយលេខ ៤៨៦/២០១៨ គព ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះវិហារ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ០៩យប់ ឈ្មោះ[redacted]លេង បានធ្វើសកម្មភាពចាប់រំលោភសេពសន្ថវៈលើក្មេងស្រីរងគ្រោះឈ្មោះ [redacted] ដោយពេលនោះម្ដាយឪពុករបស់ឈ្មោះ [redacted]មិននៅផ្ទះ គាត់កាន់ចេញទៅចាប់កង្កែប ហើយឈ្មោះ [redacted] លេង គិតថាជាឱកាសល្អដោយមានតែពីរនាក់និងឈ្មោះ [redacted] ក្នុងពេលនោះឈ្មោះ [redacted] កំពុងបបរបាយជ្រូកនៅក្រោយផ្ទះ ពេលបបរបាយជ្រូករួចឈ្មោះ [redacted] ក៏បានឡើងទៅលើផ្ទះស្រាប់តែឈ្មោះ [redacted] លេង មកចាប់អោបនាងពីក្រោយរួចប្រឡេះឡេវខោនាង ស្រាតខោ និងផ្តួលនាងទៅលើក្តា រួចឈ្មោះ [redacted] លេង បានយកដៃសង្កត់ទ្រូងនាង និងបានយកលិង្គមកដាក់បញ្ចូលក្នុងប្រដាប់ភេទរបស់នាង ប៉ុន្មានទីក្រោយមកឈ្មោះ [redacted]លេង បានក្រោកពីលើនាងហើយដើរមកដេកវិញ។ លើកទី២ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល១១ព្រឹក ពេលនោះនាងកំពុងតែដេកស្រាប់តែឈ្មោះ [redacted] លេង បានចូលក្នុងបន្ទប់របស់នាង ហើយចាប់សម្រាតខោក្នុង និងបានសើយសំពត់របស់នាងរំលោភបានសម្រេច។ លើកទី៣ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង១ថ្ងៃត្រង់ នាងកំពុងស្លៀកពាក់បម្រុងងូតទឹកស្រាប់តែឈ្មោះ [redacted]លេង បានចូលទៅអោបហើយផ្តួលនាងទៅនិងកន្ទេលរួចធ្វើសកម្មភាពបានសម្រេច។ ក្រោយមកទើបម្ដាយជនរងគ្រោះដឹងរឿង និងបានដាក់ពាក្យបណ្ដឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកតុលាការតែម្តង។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] លេង ឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៧ ដោយគេចោទថាខ្លួនរំលោភឈ្មោះ [redacted]។ លើកទី១ គេចោទថាខ្លួននៅផ្ទះតែពីរនាក់ ពេលនោះខ្លួនបានប្រាប់ថានៅគ្នាបីនាក់ ហើយខាងស្រីក៏ឆ្លើយថា នៅបីនាក់ដែរ ពេលដែលឆ្លើយនៅប៉ុស្តិ៍។ ខ្លួនបានទៅពីខេត្តកំពង់ធំ ដើម្បីធ្វើការនៅឯកន្លែងកើតហេតុក្នុងខេត្តព្រះវិហារ ដោយខ្លួនបានធ្វើការបានប្រហែលពីរខែ ក៏មានរឿងកើតឡើង។ ផ្ទះរបស់ជនរងគ្រោះបែរមុខទៅជើង នៅលើផ្ទះគឺមានបន្ទប់ដេកមួយ ហើយបងប្រុសគេនៅទីនោះដែរថ្ងៃដែលគេ



Scanned with CamScanner

ចោទថាខ្លួនរំលោភជនរងគ្រោះ។ បងប្រុសជនរងគ្រោះ ឈ្មោះ [redacted] បានដេញខ្លួនចេញពីផ្ទះ ហើយខ្លួនក៏បានចេញទៅនៅផ្ទះគ្រូម្នាក់នៅទល់មុខ ហើយពីទៅបីថ្ងៃក្រោយ ខ្លួនបានប្រាប់ថា កុំអោយកូននៅតែម្នាក់ឯង។ ពេលដែលគ្រួសារឈ្មោះ [redacted] មានរឿងឈ្លោះគ្នាក្នុងគ្រួសារ ខ្លួនក៏បានទៅជួយឃាត់ ហើយបងស្រីគេក៏ដេញខ្លួនចេញពីផ្ទះដែរ។ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ខ្លួននៅផ្ទះ [redacted] មានគ្នាបីនាក់ មានខ្លួន បងប្រុសរបស់ [redacted] ឈ្មោះ [redacted] និង [redacted] ហើយខ្លួនអត់បានរំលោភជនរងគ្រោះឈ្មោះ [redacted] នោះទេ។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ គេហៅខ្លួនទៅសួរ តែខ្លួននៅក្រោមផ្ទះអត់ដឹងរឿងអ្វីទេ។ ពេលដែលខ្លួនបានចេញពីផ្ទះ [redacted] បានប្រហែល ១០ថ្ងៃ ទើបគេប្តឹងខ្លួន។ ខ្លួនពុំបានរំលោភទៅលើជនរងគ្រោះនោះទេ មូលហេតុដែលខ្លួននិយាយថា បើទុកកូននៅម្នាក់ឯងនិងខ្មាស់គេ ព្រោះជនរងគ្រោះបានប្រាប់ខ្លួនថា បងប្រុសរបស់គាត់ឈ្មោះ [redacted] បានចាប់រំលោភ នាងនៅស្រែ។ ខ្លួនបាននិយាយលេងថា ខ្លួនស្រលាញ់ ហើយខ្លួនបានសួរហើយគាត់បានប្រាប់ខ្លួន។ ខ្លួនដឹងនៅពេលដែលឈ្មោះ [redacted] បានមករកលុយពីជនរងគ្រោះ ខ្លួនបានឃើញឈ្មោះ [redacted] ប្រគាយប្រគប់ជាមួយជនរងគ្រោះនៅខាងក្នុងបន្ទប់ដេក។ ខ្លួនធ្លាប់និយាយលេងជាមួយជនរងគ្រោះធម្មតា។ ខ្លួននៅផ្ទះជនរងគ្រោះប្រហែល២ខែ ហើយគេដេញខ្លួនចេញ។ ខ្លួនទើបតែស្គាល់ជនរងគ្រោះដែរ ហើយគ្មានគំនុំជាមួយគ្នាទេ ខ្លួនពុំទទួលស្គាល់នោះទេ ចំពោះការដែលគេចោទថាខ្លួនរំលោភសេពសន្ថវៈលើឈ្មោះ [redacted]។ ខ្លួនអត់បានរំលោភជនរងគ្រោះនោះទេ អត់បានរំលោភទាំងបីលើក។ខ្លួនបានដឹងថាឈ្មោះ [redacted] រំលោភជនរងគ្រោះឈ្មោះ [redacted] ខ្លួនដឹងដោយសារតែជនរងគ្រោះបានប្រាប់ខ្លួនថាបងប្រុសគាត់ឈ្មោះ [redacted] បានរំលោភគាត់នៅស្រែ។ ខ្លួនបានប្រាប់អ៊ុំស្រីបង្កើតជនរងគ្រោះ ខ្លួនអត់ចាំឈ្មោះអ៊ុំនោះទេ។

[redacted]

-ជនរងគ្រោះឈ្មោះ [redacted] ឆ្លើយថា៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ខ្លួនដាក់បាយជ្រូកបន្ទាប់មកខ្លួនបានឡើងទៅលើផ្ទះស្រាប់តែឈ្មោះ [redacted] លេង បានចាប់អោបខ្លួនពីក្រោយនៅលើជណ្តើរ ហើយបានផ្តួលខ្លួន បន្ទាប់មកគាត់បានស្រាតខោខ្លួន ដល់ជើងនិងរំលោភរហូតបានសម្រេច រួចហើយគាត់បានដើរទៅដេកវិញ។ ពេលដែលគេរំលោភខ្លួននោះបងប្រុសខ្លួនឈ្មោះ [redacted] ក៏នៅទីនោះដែរ ពេលដែលគេចាប់រំលោភខ្លួននោះ ខ្លួនអត់បានស្រែអោយគេជួយនោះទេ ពេលដែលរំលោភខ្លួននោះ គាត់អត់បានគម្រាម ឬមានអាវុធនៅនឹងដៃនោះទេ។ ខ្លួនភ័យពេកបានខ្លួនអត់ស្រែក។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ម្តាយខ្លួនបានទៅរកគោជាមួយឪពុករបស់ខ្លួន ហើយខ្លួននៅផ្ទះតែពីរនាក់ ហើយជនជាប់ចោទចាប់ខ្លួននៅលើផ្ទះក្នុងបន្ទប់ដេក។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ជនជាប់ចោទបានចាប់ខ្លួនម្តងទៀត ហើយគាត់បានប្រាប់ខ្លួនថា ពេលដែលគាត់មានប្រាក់ចាំគាត់ចូលស្តីដណ្តឹង។ បងប្រុសរបស់ខ្លួនឈ្មោះ [redacted] បាននិយាយស្តីអោយជនជាប់ចោទថា "អាមនុស្សស៊ីបានបោកឆ្នាំង" ហើយជនជាប់ចោទក៏ឈ្លោះគ្នាជាមួយបងប្រុសខ្លួនឈ្មោះ [redacted] បន្ទាប់មកបងខ្លួនក៏ដេញអោយចេញពីផ្ទះតែម្តង។ ពេលដែលគាត់ចាប់រំលោភខ្លួននោះ ខ្លួនពុំបានយល់ព្រមជាមួយគាត់នោះទេ។

-ដើមបណ្តឹងឈ្មោះ [redacted] ឆ្លើយថា៖ កូនប្រុសរបស់ខ្លួនឈ្មោះ [redacted] បានប្រាប់ខ្លួនថា "ជាងស៊ីបាយបោកឆ្នាំង" និងបានប្រគាយប្រគប់ជាមួយខ្លួន។ ក្រោយមកខ្លួនបានអង្កេតហើយបានសួរកូនស្រីខ្លួន ទើបដឹងថា ជាងរំលោភកូនរបស់ខ្លួនចំនួន

បីដង។ ពេលដែលខ្លួនឈ្លោះគ្នាជាមួយកូនប្រុសរបស់ខ្លួនឈ្មោះ [redacted] ជាងឈ្មោះ [redacted] លេង បានចូលមកឃាត់ដែរ ក្រោយមកកូនរបស់ខ្លួនក៏បានដេញជាងចេញពីផ្ទះ។ ឈ្មោះ [redacted] លេង បានជំពាក់ប្រាក់ខ្លួនចំនួន ២០,០០០(ពីរម៉ឺន)រៀល ហើយគាត់បានសងខ្លួនចំនួន ១០០,០០០(មួយសែន)រៀលវិញ។ ខ្លួនអត់បានឃើញឈ្មោះ [redacted] លេងរំលោភសេពសន្ថវៈកូនស្រីរបស់ខ្លួនឈ្មោះ [redacted] ដោយផ្ទាល់នោះទេ។ អ៊ុំស្រីម្នាក់ដែលឈ្មោះ [redacted] លេង និយាយថា គាត់បានប្រាប់រឿងរ៉ាវកូនត្រូវបងប្រុសរំលោភនោះ គឺគាត់ឈ្មោះ [redacted] ភេទស្រី រស់នៅភូមិក្តុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ។ សុំអោយតុលាការជួយរកយុត្តិធម៌ ខ្លួនសុំទាមទារសំណងជម្ងឺចិត្តពីជនជាប់ចោទចំនួន ៣,០០០(បីពាន់)ដុល្លារអាមេរិក។

-សាក្សីឈ្មោះ [redacted] ឆ្លើយថា៖ ខ្លួនអត់ដឹងរឿងអ្វីនោះទេ តែខ្លួនបានដេកលើអង្រឹងនោះខ្លួនអត់បានឃើញអ្វីទេ ខ្លួនដឹងថា មានភ្លើផ្ទុះ ស្មានតែឆ្កែឡើងមកលើផ្ទះ។ កន្លែងដែលខ្លួនចងអង្រឹងនោះខ្លួនមើលអត់ឃើញនោះទេទាំងខាងមុខ ព្រោះកន្លែងចងអង្រឹងប្រហែល១៥ម៉ែត្រ ណាមួយខ្លួនអស់កម្លាំងផង។

**មេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋាន**

ជនជាប់ចោទបានបដិសេធថា គាត់អត់បានរំលោភសេពសន្ថវៈទាំងបីលើកទៅលើជនរងគ្រោះនោះទេ។ ជនជាប់ចោទបានរំលោភជនរងគ្រោះនៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៧ ពេលដែលជនរងគ្រោះឡើងផុតជណ្តើរបន្តិច មានសាក្សីជាបងប្រុសរបស់ជនរងគ្រោះ គាត់បានដេកនៅបន្ទប់ទល់មុខបន្ទប់របស់ប្អូនរបស់គាត់ដែលជាជនរងគ្រោះ ហើយសាក្សីក៏អស់កម្លាំងហើយដេកលក់ តែសាក្សីក៏ដឹងថាមានការរង្គើផ្ទះដែរហើយគាត់ស្មានតែឆ្កែឡើងផ្ទះ។ នៅពេលជនជាប់ចោទរំលោភទាំងបីលើក កូនក្តីរបស់ខ្លួន គាត់អត់សូវចេះនិយាយអ្វីទេ ចរិតពីធម្មជាតិ ហើយគាត់ក៏មានអារម្មណ៍ភ័យខ្លាចផងដែរ។ ជនជាប់ចោទពុំសារភាពទទួលនូវកំហុសរបស់គាត់ទេ សូមតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសម្រេចអោយជនជាប់ចោទសងសំណងជម្ងឺចិត្តដូចដែលដើមបណ្តឹងរដ្ឋប្បវេណីជាកូនក្តីរបស់ខ្លួនទាមទារ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,ចម្លើយរបស់ជនរងគ្រោះ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សីឃើញថា៖ ជនជាប់ចោទពិតជាបានរំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ [redacted] ប្រាកដមែន។ ហេតុដូច្នេះ តំណាងអយ្យការ សុំតម្កល់បទចោទនៅដដែល គឺបទ **រំលោភសេពសន្ថវៈ(ស្ថានទម្ងន់ទោសដោយសារមូលហេតុអាយុជនរងគ្រោះ)** ប្រព្រឹត្ត [redacted] កាលពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំណុច ១ នៃក្រមព្រហ្មទណ្ឌ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន**

ក្រោយពីពិភាក្សាដេញដោលរួចមកឃើញថា៖ ជនរងគ្រោះត្រូវបានបងប្រុសបង្កើតរបស់គាត់ដែលមានឈ្មោះ [redacted] ជាអ្នករំលោភប្អូនស្រីខ្លួនឈ្មោះ [redacted] ដែលវាពុំមែនជាកូនក្តីរបស់ខ្លួនជាអ្នករំលោភនោះទេ ហើយកូនក្តីរបស់ខ្លួនក៏បានបញ្ជាក់ផងដែរថា មានសាក្សីផ្សេងទេដឹងរឿងឈ្មោះ [redacted] រំលោភជនរងគ្រោះ ហេតុនេះខ្លួនជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទស្នើសុំដល់តុលាការចាត់របៀប ដើម្បីធ្វើការប្រមូលភស្តុតាងនៅកន្លែងកើតហេតុផង ក្នុងការរកយុត្តិធម៌ជូនកូនក្តីរបស់ខ្លួនផង។



Scanned with CamScanner

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] លេង ខ្លួនសុំអោយតុលាការសម្រេចអោយខ្លួនរួចផុតពីបទចោទ ព្រោះខ្លួនអត់បានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចម្លើយសាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី១៦,ថ្ងៃទី១៧ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ស្ថិតនៅភូមិក្តុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ មានករណីរំលោភសេពសន្ថវៈ ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] លេង ភេទប្រុស ទៅលើជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ១៧ឆ្នាំ បានសម្រេចប្រាកដមែន។

២.នាពេលសវនាការជនជាបចោទឈ្មោះ [redacted] លេង ឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៧ ដោយគេចោទថាខ្លួនរំលោភឈ្មោះ [redacted]។ លើកទី១ គេចោទថាខ្លួននៅផ្ទះតែពីរនាក់ ពេលនោះខ្លួនបានប្រាប់ថា នៅគ្នាបីនាក់ ហើយខាងស្រីក៏ឆ្លើយថា នៅបីនាក់ដែរ ពេលដែលឆ្លើយនៅប៉ុស្តិ៍។ ខ្លួនបានទៅពីខេត្តកំពង់ធំ ដើម្បីធ្វើការនៅឯកន្លែងកើតហេតុក្នុងខេត្តព្រះវិហារ ដោយខ្លួនបានធ្វើការបានប្រហែលពីរខែ ក៏មានរឿងកើតឡើង។ ផ្ទះរបស់ជនរងគ្រោះបែរមុខទៅជើង នៅលើផ្ទះគឺមានបន្ទប់ដេកមួយ ហើយបងប្រុសគេនៅទីនោះដែរថ្ងៃដែលគេចោទថាខ្លួនរំលោភជនរងគ្រោះ។ បងប្រុសជនរងគ្រោះ ឈ្មោះ [redacted] បានដេញខ្លួនចេញពីផ្ទះ ហើយខ្លួនក៏បានចេញទៅនៅផ្ទះគ្រូម្នាក់នៅទល់មុខ ហើយពីទៅបីថ្ងៃក្រោយ ខ្លួនបានប្រាប់ថា កុំអោយកូននៅតែម្នាក់ឯង។ ពេលដែលគ្រួសារឈ្មោះ [redacted] មានរឿងឈ្លោះគ្នាក្នុងគ្រួសារ ខ្លួនក៏បានទៅជួយឃាត់ ហើយបងស្រីគេក៏ដេញខ្លួនចេញពីផ្ទះដែរ។ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ខ្លួននៅផ្ទះ [redacted] មានគ្នាបីនាក់ មានខ្លួន បងប្រុសរបស់ [redacted] ឈ្មោះ [redacted] និង [redacted] ហើយខ្លួនអត់បានរំលោភជនរងគ្រោះឈ្មោះ [redacted] នោះទេ។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ គេហៅខ្លួនទៅសួរ តែខ្លួននៅក្រោមផ្ទះអត់ដឹងរឿងអ្វីទេ។ ពេលដែលខ្លួនបានចេញពីផ្ទះ [redacted] បានប្រហែល ១០ថ្ងៃ ទើបគេប្តឹងខ្លួន។ ខ្លួនពុំបានរំលោភទៅលើជនរងគ្រោះនោះទេ មូលហេតុដែលខ្លួននិយាយថា បើទុកកូននៅម្នាក់ឯង និងខ្មាស់គេ ព្រោះជនរងគ្រោះបានប្រាប់ខ្លួនថា បងប្រុសរបស់គាត់ឈ្មោះ [redacted] បានចាប់រំលោភ នាងនៅស្រែ។ ខ្លួនបាននិយាយលេងថា ខ្លួនស្រលាញ់ ហើយខ្លួនបានសួរហើយគាត់បានប្រាប់ខ្លួន។



Scanned with CamScanner

ខ្លួនដឹងនៅពេលដែលឈ្មោះ [redacted] បានមករកលុយពីជនរងគ្រោះ ខ្លួនបានឃើញឈ្មោះ [redacted] ប្រតាយប្រតប់ជាមួយជនរងគ្រោះនៅខាងក្នុងបន្ទប់ដេក។ ខ្លួនធ្លាប់និយាយលេងជាមួយជនរងគ្រោះធម្មតា។ ខ្លួននៅផ្ទះជនរងគ្រោះប្រហែល២ខែ ហើយគេដេញខ្លួនចេញ។ ខ្លួនទើបតែស្គាល់ជនរងគ្រោះដែរ ហើយគ្មានគំនុំជាមួយគ្នាទេ ខ្លួនពុំទទួលស្គាល់នោះទេ ចំពោះការដែលគេចោទ ថាខ្លួនរំលោភសេពសន្ថៈលើឈ្មោះ [redacted]។ ខ្លួនអត់បានរំលោភជនរងគ្រោះនោះទេ អត់បានរំលោភទាំងបីលើក។ខ្លួនបានដឹងថាឈ្មោះ [redacted] រំលោភជនរងគ្រោះឈ្មោះ [redacted] ខ្លួនដឹងដោយសារតែជនរងគ្រោះបានប្រាប់ខ្លួនថាបងប្រុសគាត់ឈ្មោះ [redacted] បានរំលោភគាត់នៅស្រែ។ ខ្លួនបានប្រាប់អ៊ុំស្រីបង្កើតជនរងគ្រោះ ខ្លួនអត់ចាំឈ្មោះអ៊ុំនោះទេ។ ចម្លើយបដិសេធរបស់ជនជាប់ចោទនេះគ្រាន់តែជាសេសដោះសារដើម្បីអោយរួចផុតពីបទចោទប្រកាន់តែប៉ុណ្ណោះ។

៣.នាពេលសវនាការជនរងគ្រោះឈ្មោះ [redacted] ឆ្លើយថា៖ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ខ្លួនដាក់បាយជ្រូកបន្ទាប់មកខ្លួនបានឡើងទៅលើផ្ទះស្រាប់តែឈ្មោះ [redacted] លេង បានចាប់អោបខ្លួនពីក្រោយនៅលើជណ្តើរ ហើយបានផ្តួលខ្លួន បន្ទាប់មកគាត់បានស្រាតខោខ្លួន ដល់ជើងនិងរំលោភរហូតបានសម្រេច រួចហើយគាត់បានដើរទៅដេកវិញ។ ពេលដែលគេរំលោភខ្លួននោះបងប្រុសខ្លួនឈ្មោះ [redacted] ក៏នៅទីនោះដែរ ពេលដែលគេចាប់រំលោភខ្លួននោះ ខ្លួនអត់បានស្រែអោយគេជួយនោះទេ ពេលដែលរំលោភខ្លួននោះ គាត់អត់បានគម្រាម ឬមានអាវុធនៅនឹងដៃនោះទេ។ ខ្លួនភ័យពេកបានខ្លួនអត់ស្រែក។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ម្តាយខ្លួនបានទៅរកគោជាមួយឪពុករបស់ខ្លួន ហើយខ្លួននៅផ្ទះតែពីរនាក់ ហើយជនជាប់ចោទចាប់ខ្លួននៅលើផ្ទះក្នុងបន្ទប់ដេក។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ជនជាប់ចោទបានចាប់ខ្លួនម្តងទៀត ហើយគាត់បានប្រាប់ខ្លួនថា ពេលដែលគាត់មានប្រាក់ចាំគាត់ចូលស្តីដណ្តឹង។ បងប្រុសរបស់ខ្លួនឈ្មោះ [redacted] បាននិយាយស្តីអោយជនជាប់ចោទថា “អាមនុស្សស៊ីបានបោកឆ្នាំង” ហើយជនជាប់ចោទក៏ឈ្លោះគ្នាជាមួយបងប្រុសខ្លួនឈ្មោះ [redacted] បន្ទាប់មកបងខ្លួនក៏ដេញអោយចេញពីផ្ទះតែម្តង។ ពេលដែលគាត់ចាប់រំលោភខ្លួននោះ ខ្លួនពុំបានយល់ព្រមជាមួយគាត់នោះទេ។ ចម្លើយរបស់ជនរងគ្រោះនេះមានភាពស្របគ្នាទៅនឹងរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌,ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងនានា ដែលមានក្នុងរឿងអាចបញ្ជាក់ថា ជនជាប់ចោទពិតជាបាន រំលោភសេពសន្ថវៈ ទៅលើជនរងគ្រោះឈ្មោះ [redacted] ប្រាកដមែន។

៥នាពេលសវនាការដើមបណ្តឹងឈ្មោះ [redacted] ឆ្លើយថា៖ កូនប្រុសរបស់ខ្លួនឈ្មោះ [redacted] បានប្រាប់ខ្លួនថា “ជាងស៊ីបាយបោកឆ្នាំង” និងបានប្រតាយប្រតប់ជាមួយខ្លួន។ ក្រោយមកខ្លួនបានបើបរអង្គរ ហើយបានសួរកូនស្រីខ្លួន ទើបដឹងថា ជាងរំលោភកូនរបស់ខ្លួនចំនួនបីដង។ ពេលដែលខ្លួនឈ្លោះគ្នាជាមួយកូនប្រុសរបស់ខ្លួនឈ្មោះ [redacted] ជាងឈ្មោះ [redacted] លេង បានចូលមកឃាត់ដែរ ក្រោយមកកូនរបស់ខ្លួនក៏បានដេញជាងចេញពីផ្ទះ។ ឈ្មោះ [redacted] លេង បានជំពាក់ប្រាក់ខ្លួនចំនួន ២០,០០០(ពីរម៉ឺន)រៀល ហើយគាត់បានសងខ្លួនចំនួន ១០០,០០០(មួយសែន)រៀលវិញ។ ខ្លួនអត់បានឃើញឈ្មោះ [redacted] លេង រំលោភសេពសន្ថវៈ កូនស្រីរបស់ខ្លួនឈ្មោះ [redacted] ដោយផ្ទាល់នោះទេ។ អ៊ុំស្រីម្នាក់ដែលឈ្មោះ [redacted] លេង និយាយថា គាត់បានប្រាប់រឿងរ៉ាវកូនត្រូវបងប្រុសរំលោភនោះ គឺគាត់ឈ្មោះ [redacted] ភេទស្រី រស់នៅភូមិក្តុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ។ សុំអោយតុលាការ

ជួយរកយុត្តិធម៌ ខ្លួនសុំទាមទារសំណង់ជម្ងឺចិត្តពីជនជាប់ចោទចំនួន ៣,០០០(បីពាន់)ដុល្លារអាមេរិក។ ចម្លើយបញ្ជាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ បង្ហាញអោយឃើញថា នៅថ្ងៃកើតហេតុដើមបណ្ដឹងរដ្ឋប្បវេណីពុំឃើញហេតុការណ៍ដោយផ្ទាល់នោះទេ ពោលដឹងតាមការប្រាប់ពីជនរងគ្រោះ។

៦.នាពេលសវនាការសាក្សីឈ្មោះ [redacted] ឆ្លើយថា៖ ខ្លួនអត់ដឹងរឿងអ្វីនោះទេ តែខ្លួនបានដេកលើអង្រឹងនោះខ្លួនអត់បានឃើញអ្វីទេ ខ្លួនដឹងថា មានភ្លើងផ្ទុះ ស្នាក់តែភ្លើងឡើងមកលើផ្ទះ។ កន្លែងដែលខ្លួនចងអង្រឹងនោះ ខ្លួនមើលអត់ឃើញនោះទេទៅខាងមុខ ព្រោះកន្លែងចងអង្រឹងប្រហែល១២ម៉ែត្រ ណាមួយខ្លួនអស់កម្លាំងផង។ ចម្លើយនេះបង្ហាញថា នៅថ្ងៃកើតហេតុសាក្សីពុំបានដឹងថាមានរឿងអ្វីកើតឡើងនោះដែរ។

៧.តាមលទ្ធផលកោសល្យវិច័យ(ឯកសារពិនិត្យការរំលោភផ្លូវភេទ) របស់មន្ទីរសុខាភិបាលខេត្តព្រះវិហារលេខ ០៩/១៧ ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៧ បង្ហាញអោយឃើញថា ជនរងគ្រោះពិតជាមានការដាច់សន្ទះព្រហ្មចារី ពិតប្រាកដមែនដែលស្របនឹងចម្លើយរបស់ជនរងគ្រោះ។

៨.តាមសំបុត្របញ្ជាក់កំណើតលេខ ១២៦ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០០២ របស់មេឃុំម្លូព្រៃមួយ បង្ហាញអោយឃើញថា អាយុជនរងគ្រោះគិតត្រឹមថ្ងៃកើតហេតុគឺ ១៧ឆ្នាំ ប៉ុណ្ណោះ។

៩.ជនជាប់ចោទជានីតិជន ដែលមានសមត្ថភាពទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌបាន ពោលគឺជនជាប់ចោទពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

១០.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការរំលោភសេពសន្ថវៈលើជនរងគ្រោះ ដែលអំពើនេះគឺជាអំពើ រំលោភសេពសន្ថវៈ ដែលច្បាប់តម្រូវឲ្យធ្វើការផ្តន្ទាទោស។

១១.មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] លេង ភេទប្រុស ពីបទ រំលោភសេពសន្ថវៈ (មានស្ថានទម្ងន់ទោសទាក់ទងទៅនឹងអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិក្តុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ កថាខណ្ឌ១ នៃក្រមព្រហ្មទណ្ឌ។

១២.អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់រាងកាយរបស់អ្នកដទៃ ,របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងកិត្តិយស សេចក្តីថ្លៃថ្នូររបស់បុគ្គលដែលច្បាប់ការពារ។

១៣.ដើមបណ្ដឹងរដ្ឋប្បវេណីបានទាមទារសំណងជម្ងឺចិត្តចំនួន ៣,០០០(បីពាន់)ដុល្លារអាមេរិក គប្បីតុលាការពិនិត្យ និងសម្រេចអំពីសំណង។

១៤.ការស្នើសុំរបស់តំណាងអយ្យការ គឺសុំតម្កល់បទចោទនៅដដែល។ ការស្នើសុំនេះមានលក្ខណៈ ត្រឹមត្រូវដែលតុលាការគប្បីពិចារណាតាមច្បាប់។

១៥.ការស្នើសុំរបស់មេធាវីការពារសិទ្ធិអោយជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី ដោយបានស្នើសុំថា៖ ជនជាប់ចោទបានបដិសេធថា គាត់អត់បានរំលោភសេពសន្ថវៈទាំងបីលើកទៅលើជនរងគ្រោះនោះទេ។ ជនជាប់ចោទបាន



Scanned with CamScanner

រំលោភជនរងគ្រោះនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ពេលដែលជនរងគ្រោះឡើងផុតជណ្តើរបន្តិច មានសាក្សីជាបងប្រុសរបស់ជនរងគ្រោះ គាត់បានដេកនៅបន្ទប់ទល់មុខបន្ទប់របស់ប្អូនរបស់គាត់ដែលជាជនរងគ្រោះ ហើយសាក្សីក៏អស់កម្លាំងហើយដេកលក់ តែសាក្សីក៏ដឹងថាមានការរង្គើផ្ទះដែរហើយគាត់ស្មានតែឆ្កែឡើងផ្ទះ។ នៅពេលជនជាប់ចោទរំលោភទាំងបីលើក កូនក្តីរបស់ខ្លួន គាត់អត់សូវចេះនិយាយអ្វីទេ ចរិតពីធម្មជាតិ ហើយគាត់ក៏មានអារម្មណ៍ភ័យខ្លាចផងដែរ។ ជនជាប់ចោទពុំសារភាពទទួលនូវកំហុសរបស់គាត់ទេ សូមតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសម្រេចអោយជនជាប់ចោទសងសំណងជម្ងឺចិត្តដូចដែលដើមបណ្តឹងរដ្ឋប្បវេណីជាកូនក្តីរបស់ខ្លួនទាមទារ តុលាការគប្បីពិចារណាតាមច្បាប់។

១៦.ការស្នើសុំរបស់មេធាវីការពារសិទ្ធិអោយជនជាប់ចោទដោយស្នើសុំអោយតុលាការពិចារណា និងសម្រេចថា៖ ក្រោយពីពិភាក្សាដេញដោលរួចមកឃើញថា ជនរងគ្រោះត្រូវបានបងប្រុសបង្កើតរបស់គាត់ដែលមានឈ្មោះ [redacted] ជាអ្នករំលោភប្អូនស្រីខ្លួនឈ្មោះ [redacted] ដែលវាពុំមែនជាកូនក្តីរបស់ខ្លួនជាអ្នករំលោភនោះទេ ហើយកូនក្តីរបស់ខ្លួនក៏បានបញ្ជាក់ផងដែរថា មានសាក្សីផ្សេងទេដឹងរឿងឈ្មោះ [redacted] រំលោភជនរងគ្រោះ ហេតុនេះខ្លួនជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទស្នើសុំដល់តុលាការចាត់របៀប ដើម្បីធ្វើការប្រមូលភស្តុតាងនៅកន្លែងកើតហេតុផងក្នុងការរកយុត្តិធម៌ជូនកូនក្តីរបស់ខ្លួនផង តុលាការគប្បីពិចារណាតាមច្បាប់។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លេខ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **០៨(ប្រាំបី)ឆ្នាំ** ពីបទ រំលោភសេពសន្ថវៈ(ស្ថានទម្ងន់ទោសដោយសារមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្តនៅ [redacted] កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ចំណុច ១ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted] **លេខ** សងសំណងការខូចខាត និងជម្ងឺចិត្តទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងជនរងគ្រោះឈ្មោះ [redacted] ចំនួន ៤,000,000(បួនលាន)រៀល ការទាមទារលើសពីនេះត្រូវច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ចំពោះមុខជនរងគ្រោះ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះនិងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសសាធារណៈនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted] [redacted] [redacted] [redacted]